01116788

E330/1/1

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 16 / 07 / 2015
ម៉ោង (Time/Heure) : 15:05
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

## គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

**ប្រធានគណៈមេធាវី**
មេធាវី ប៊ុន ហុន

**ក្រុមប្រឹក្សាគណៈមេធាវី**
១-មេធាវី ម៉ា ចូនគា
២-មេធាវី កែវ ជា
៣-មេធាវី ហាក់ សៀកលី
៤-មេធាវី ចំនួ ទិចិត្រ
៥-មេធាវី ចេង ប៉េងហាប់
៦-មេធាវី ជុង ជូទី
៧-មេធាវី លី ចន្ទតុលា
៨-មេធាវី តែ ចំណាន
៩-មេធាវី ទិច សុទាចា
១០-មេធាវី ពេជ្រ សុរិយា
១១-មេធាវី គង់ នីលីន
១២-មេធាវី យុង ផានិត
១៣-មេធាវី លឹម ទណ្ណា
១៤-មេធាវី សុក ស៊ីផាន់ណា
១៥-មេធាវី ស្រ៊ី គឹមយូ
១៦-មេធាវី កុយ នាម
១៧-មេធាវី ឆូច ធីរិទ្ធ
១៨-មេធាវី គឹម ទាសនា
១៩-មេធាវី សួស សាមឿន
២០-មេធាវី ខូន មករា
២១-មេធាវី លឹម អេងគេង:
២២-មេធាវី ហុង គឹមសួន
២៣-មេធាវី ឯក មាលា
២៤-មេធាវី ឡុង ដារ៉ា
២៥-មេធាវី ស៊ួង ចាន់ថន
២៦-មេធាវី ស សុខាន
២៧-មេធាវី លៀង ចិន្តា

លេខ : ១៥០៤/គ.ម/១៥

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៥

សាធារណៈ / Public

**សូមគោរពជូន**

**ឯកឧត្តមប្រធានអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**កម្មវត្ថុ:** ការពិនិត្យលើការប្រព្រឹត្តរបស់លោកមេធាវី គង់ សំអុន នៅក្នុងនីតិវិធីនៃសំណុំរឿង ០០២/០២។

**យោង:**
- ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥។
- ក្រមសីលធម៌មេធាវី ឆ្នាំ២០១២។
- ដីកាបញ្ជូនការប្រព្រឹត្តិរបស់មេធាវីការពារក្តី ខៀវ សំផន ទៅអង្គភាពមានសមត្ថកិច្ច ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ របស់ អ.វ.ត.ក. (ឯកសារ E330)។
- លិខិតចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ របស់ចៅក្រម និល ណុន ផ្ញើជូនប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (ឯកសារ E330/1)។
- លិខិតចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៤ របស់លោកមេធាវី គង់ សំអុន។
- ពាក្យសុំអន្តរាគមន៍ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់លោកមេធាវី គង់ សំអុន។
- លិខិតបំភ្លឺចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ របស់លោកមេធាវី គង់ សំអុន។
- ការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ បន្ទាប់ពីទទួលបានលិខិតចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ របស់ **ឯកឧត្តមប្រធាន** រួចមក គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាគណៈមេធាវី ដើម្បីពិភាក្សា និងសម្រេច លើករណីការប្រព្រឹត្តរបស់លោកមេធាវី គង់ សំអុន ដូចតទៅ៖

### ក. អំពីអង្គហេតុ

១. លោកមេធាវី គង់ សំអុន ជាមេធាវីនៃក្រុមមេធាវីការពារក្តីឱ្យលោក ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២។ សំណុំរឿង ០០២/០១ ត្រូវបានបញ្ចប់នៅ

អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. និងបើកផ្លូវឱ្យប្តឹងសារទុក្ខរហូតដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤។ មុនផុតរយៈពេលប្តឹងសារទុក្ខនេះ អង្គជំនុំជម្រះសាលាដំបូងបានកំណត់កាលបរិច្ឆេទសម្រាប់សវនាការដេញដោលលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ ដែលចាប់ផ្តើមពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤។

២. នៅមុនថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ លោក **ខៀវ សំផន** និងក្រុមមេធាវីការពារឱ្យរូបលោក ដែលក្នុងនោះមានលោកមេធាវី **គង់ សំអុន** ធ្លាប់បានធ្វើសំណើទៅអង្គជំនុំជម្រះសាលាដំបូងឱ្យធ្វើការពិចារណាឡើងវិញលើការកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២។

៣. នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ លោកមេធាវី **គង់ សំអុន** និងសហមេធាវីអន្តរជាតិ បានចង្អុលបង្ហាញថាពួកគេមិនចង់ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ទេ រហូតទាល់តែពួកគេដាក់សារណាបណ្តឹងសារទុក្ខក្នុងសំណុំរឿង ០០២/០១ រួចរាល់សិន ហើយបានចាកចេញពីបន្ទប់សវនាការ។

៤. លោកមេធាវី **គង់ សំអុន** បានលើកមូលហេតុសំខាន់ ២ មកបញ្ជាក់ពីព្រឹត្តការនៃការចាកចេញពីបន្ទប់សវនាការកាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ នេះៈ

- មេធាវីពុំមានធនធានគ្រប់គ្រាន់ និង
- មេធាវីទទួលបានការណែនាំពីកូនក្តី (លោក **ខៀវ សំផន**) ឱ្យយកចិត្តទុកដាក់ ចំណាយពេលវេលា និងធនធានទាំងអស់ដែលមានលើការធ្វើបណ្តឹងសារទុក្ខនៃសំណុំរឿង ០០២/០១ និងបានណែនាំមេធាវីមិនឱ្យចូលសវនាការលើសំណុំរឿង ០០២/០២ រហូតដល់ផុតរយៈពេលប្តឹងសារទុក្ខ។

៥. អង្គជំនុំជម្រះសាលាដំបូងក៏បានខិតខំប្រឹងប្រែងដើម្បីជួយសម្រួលដល់ជនជាប់ចោទ និងក្រុមមេធាវីការពារក្តីឱ្យជនជាប់ចោទ ដោយធ្វើការពន្យាកាលបរិច្ឆេទសវនាការ និងបន្ថយចំនួនថ្ងៃធ្វើសនវការលើសំណុំរឿង ០០២/០២។

៦. សវនាការលើសំណុំរឿង ០០២/០២ ត្រូវបានរៀបចំជាថ្មីម្តងទៀតនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ ហើយលោកមេធាវី **គង់ សំអុន** ក៏ទទួលបានការយល់ព្រមពីកូនក្តីឱ្យចូលរួមសវនាការ ដើម្បីបង្ហាញជំហរមិនអាចចូលរួមសវនាការនាពេលខាងមុខបានទេ រហូតដល់ផុតរយៈពេលធ្វើបណ្តឹងសារទុក្ខ ពោលគឺរហូតដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ដើម្បីការពារផលប្រយោជន៍របស់កូនក្តីនៅក្នុងសំណុំរឿង ០០២/០១។

**ខ. អំពីអង្គច្បាប់**

១. មាត្រា ១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចែងថា "វិជ្ជាជីវៈមេធាវីជាវិជ្ជាជីវៈឯករាជ្យ និងសេរី ដែលចូលរួមបម្រើវិស័យយុត្តិធម៌"។

២. កថាខណ្ឌទី ២ ទី ៣ និងទី ៤ នៃមាត្រា ៣៧ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២ ចែងថាៈ

"មេធាវីត្រូវប្រកាន់ ឱ្យបានខ្ជាប់ខ្ជួននូវឯករាជ្យ និងសេចក្តីថ្លៃថ្នូរក្នុងវិជ្ជាជីវៈ នៅចំពោះមុខតុលាការ។ មេធាវីត្រូវគោរពតាមវិធាន នីតិវិធី និងបទបញ្ជារបស់តុលាការ។ មេធាវីមិនត្រូវប្រើជាដាច់ខាតនូវវិធីមិនស្មោះត្រង់ ហើយត្រូវគោរពវិធីតទល់គ្នា។

មេធាវីមានសិទ្ធិសំដែងឡើងនូវអ្វីៗដែលខ្លួនយល់ថាមានប្រយោជន៍ដល់អតិថិជនរបស់ខ្លួន។"

៣. មាត្រា ៣៨ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២ ចែងថា "មេធាវីត្រូវទាមទារ និងស្វះស្វែងធ្វើឱ្យមានការ ជំនុំជម្រះក្តីដោយយុត្តិធម៌ គោរពតាមច្បាប់ និងនីតិវិធីត្រឹមត្រូវឱ្យកើតមានយ៉ាងពិតប្រាកដ។"

៤. មាត្រា ៣៩ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២ ចែងថា "មេធាវីមិនត្រូវបង្កឱ្យមានការពន្យានីតិវិធីតុលាការណាមួយ ដោយការធ្វេសប្រហែស ឬមូលហេតុមិនសមហេតុផលដែលអាចប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌នោះឡើយ"។

**គ. អំពីសំអាងហេតុ**

១. វិជ្ជាជីវៈមេធាវីជាវិជ្ជាជីវៈឯករាជ្យ និងសេរី ដែលចូលរួមបម្រើវិស័យយុត្តិធម៌ មានន័យថា នៅក្នុងការប្រកបវិជ្ជាជីវៈមេធាវី មេធាវីម្នាក់ៗមានឯករាជ្យភាពក្នុងការងារបច្ចេកទេសរបស់ខ្លួនស្របតាមវិធានវិជ្ជាជីវៈ និងបទប្បញ្ញត្តិជាធរមាននៅក្នុងការផ្តល់សេវាកម្មច្បាប់ជូនអតិថិជន ដោយមិនស្ថិតក្រោមសម្ពាធ ឬការជ្រៀតជ្រែកពីបុគ្គលណា ឬពីស្ថាប័នណាមួយឡើយ។ ដើម្បីការពារប្រយោជន៍អតិថិជន មេធាវីត្រូវការឱ្យមានការពិគ្រោះយោបល់ និងទទួលស្តាប់ការណែនាំពីអតិថិជនដែលជាម្ចាស់ផលប្រយោជន៍។ មេធាវីជាជំនួយការយុត្តិធម៌របស់សង្គម មិនមែនជាជំនួយការរបស់តុលាការទេ។ ទោះបីជាមេធាវីបំពេញការងារដើម្បីជាប្រយោជន៍របស់អតិថិជនក៏ដោយ ក៏មេធាវីមិនអាចធ្វើកិច្ចការណាដែលផ្ទុយនឹងច្បាប់ ឬមានចេតនាពន្យានីតិវិធីដោយគ្មានហេតុផលច្បាស់លាស់ទេ។

២. នៅក្នុងករណីលោកមេធាវី **គង់ សំអុន** គណៈមេធាវីយល់ឃើញថាការមិនចូលរួមនីតិវិធីសវនាការនៃសំណុំរឿង ០០២/០២ ធ្វើឡើងស្របតាមឆន្ទៈរបស់កូនក្តី ដើម្បីការពារផលប្រយោជន៍របស់កូនក្តី ដោយមិនផ្ទុយជាមួយនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ។ ការមិនព្រមចូលរួមនីតិវិធីសវនាការរបស់លោកមេធាវី **គង់ សំអុន** មិនមែនជាហេតុផលនៃការចង់ពន្យាពេលនីតិវិធីតុលាការដែលធ្វើឱ្យខូចប្រយោជន៍យុត្តិធម៌នោះទេ ពោលគឺលោកមេធាវីមានហេតុផលច្បាស់លាស់ ដែលស្របទៅតាមមាត្រា ៣៧ និងមាត្រា ៣៩ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២។ ការបដិសេធមិនចូលរួមនីតិវិធីសវនាការនៃសំណុំរឿង ០០២/០២ នេះ គឺគ្រាន់តែធ្វើឡើងដើម្បីអនុញ្ញាតឱ្យមេធាវីមានពេលវេលាគ្រប់គ្រាន់ និងប្រើប្រាស់ធនធានទាំងអស់ដែលមានលើការរៀបចំបណ្តឹងសារទុក្ខ រហូតដល់ផុតរយៈពេលនៃបណ្តឹងសារទុក្ខនៃសំណុំរឿង ០០២/០១ តែប៉ុណ្ណោះ គឺត្រឹមថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤។ កូនក្តី (លោក **ខៀវ សំផន**) និងលោកមេធាវី **គង់ សំអុន** បានបញ្ជាក់ពីជំហរនេះយ៉ាងច្បាស់លាស់ជូនអង្គជំនុំជម្រះសាលាដំបូងរួចហើយ

៣. គណៈមេធាវីពិនិត្យឃើញថា ក្រោយកាលបរិច្ឆេទថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ លោកមេធាវី គង់ សំអុន បានចូលរួមគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ នៅក្នុងសំណុំរឿង ០០២/០២ ដូចដែលលោកមេធាវី និងលោក ខៀវ សំផន បានសន្យា និងស្នើសុំតុលាការ ។

**ឃ. អំពីការសម្រេច**

បន្ទាប់ពីបានពិភាក្សាគ្នាយ៉ាងល្អិតល្អន់នាសម័យប្រជុំក្រុមប្រឹក្សាគណៈមេធាវីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥ ក្រុមប្រឹក្សាគណៈមេធាវីយល់ឃើញថា <u>ការប្រព្រឹត្តរបស់លោកមេធាវី គង់ សំអុន</u> ដែលបានរៀបរាប់នៅក្នុងឯកសារ E330 ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ របស់អង្គជំនុំជម្រះសាលាដំបូង <u>មិនមែនជាកំហុសវិជ្ជាជីវៈមេធាវី</u> នោះទេ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាជ្រាបតាមការគួរ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ៕

**ប្រធាន**

**មេធាវី. ប៊ុន-ហុន**

**ចម្លងជូន៖**
-ក្រុមប្រឹក្សាគណៈមេធាវី
-លោកមេធាវី គង់ សំអុន
-ឯកសារ-កាលប្បវត្តិ

អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ៖១៩៨៧, ទូរស័ព្ទ: (៨៥៥-២៣) ៨៦៤ ០៧៨
ទូរសារ: (៨៥៥-២៣) ៨៦៤ ០៧៦, E-mail: info@bakc.org.kh, website: www.bakc.org.kh